## រឿងទី២៖ ដាវីឌ និងកូលីយ៉ាត

**ខគម្ពីរ៖ ១សាំយូអែល១៧៖៤៥**

ដាវីឌឆ្លើយទៅវិញថា៖ «ឯងកាន់ដាវ កាន់លំពែង និងស្នមកវាយអញ រីឯអញវិញ អញមកវាយឯង ក្នុងនាមព្រះអម្ចាស់ នៃពិភពទាំងមូល ជាព្រះនៃពលទ័ពអ៊ីស្រាអែល ដែលឯងបានបំបាក់មុខ។

ដាវីឌគឺជាអ្នកគង្វាលចៀម។ ទោះដាវីឌហាត់នឿងពីការខិតខំធ្វើការជាអ្នកគង្វាលក៏ដោយ ក៏គាត់មិនភ្លេចលេងពិណសសើរតម្កើងព្រះជាម្ចាស់ដែរ។
ក្នុងចំណោមមិត្តភក្តិទាំងអស់ ដាវីឌល្បីថាជាមេដឹកនាំច្រៀងសរសើរតម្កើងដែលពូកែលេងពិណជាងគេ។ មួយវិញទៀត ដាវីឌក៏ជាអ្នកអធិស្ឋានដែលស្វាហាប់ជាងគេដែរ។
ដាវីឌ ជឿថាព្រះជាម្ចាស់តែងតែគង់នៅ និងធ្វើការជាមួយគាត់។
ពេលដាវីឌឃ្វាលហ្វូងចៀម តែងតែមានសត្វតោ និងខ្លាឃ្មុំចេញមកដើម្បីចាប់ចៀមស៊ី។
ដាវីឌនៅក្មេងខ្លាំងណាស់ ឱ្យទៅតយុទ្ធជាមួយសត្វតោ និងខ្លាឃ្មុំកាចសាហាវនោះគឺមិនអាចទៅរួចទេ។
ដូច្នេះ ដាវីឌបានអធិស្ឋានទៅព្រះជាម្ចាស់។ ដើម្បីការពារហ្វូងចៀមពីសត្វតោនិងខ្លាឃ្មុំ ដាវីឌបានហាត់រៀនគ្រវីខ្សែដង្ហក់ គប់សត្វទាំងនោះដែលចង់មកចាប់ស៊ី ហ្វូងចៀមរបស់ខ្លួន។
ពេលដាវីឌគ្រវីខ្សែដង្ហក់គប់ទៅលើសត្វតោ និងខ្លាឃ្មុំដែលកំពុងខាំពាំចៀមនិងមាត់ ត្រូវគ្មានខុស ធ្វើឱ្យសត្វទាំងនោះ ឈឺ ក៏ទម្លាក់ចៀមចុះមកវិញ រួចស្រែកយំរត់ទៅបាត់។
មានថ្ងៃមួយ ស្រុកអ៊ីស្រាអែលមានសង្គ្រាមជាមួយពួកជនជាតិភីលីស្ទីន។
ពេលនោះឪពុកបានប្រើដាវីឌឱ្យទៅជួបបងៗដែលនៅសមរភូមិ ហើយក៏បានឮកូលីយ៉ាតកំពុងនិយាយមើលងាយ រាស្ត្ររបស់ព្រះជាម្ចាស់។
ដាវីឌបានសួរទៅជនជាតិអ៊ីស្រាអែលថាហេតុអ្វីបានជាជនជាតិភីលីស្ទីននេះហ៊ាននិយាយមើលងាយដល់ទាហាន របស់ព្រះជាម្ចាស់ដូច្នេះ។
ក្រោយពីស្តាប់ពាក្យរបស់ដាវីឌហើយមានមនុស្សម្នាក់បានយកពាក្យនោះទៅប្រាប់ស្តេចសូល។ ស្តេចសូលបានឱ្យ ដាវីឌចូលទៅក្នុងព្រះរាជវាំង។
ស្តេចសូល បាននិយាយជាមួយដាវីឌ ហើយក៏អនុញ្ញាតឱ្យដាវីឌចេញទៅធ្វើសង្គ្រាម។
ដាវីឌជឿជាក់ថាព្រះជាម្ចាស់ទ្រង់នឹងជួយគាត់អាចយកឈ្នះលើកូលីយ៉ាតនិងជនជាតិភីលីស្ទីនដែលមើលងាយព្រះជាម្ចាស់ជាមិនខាន។
មុនពេលដាវីឌចេញទៅច្បាំងជាមួយកូលីយ៉ាត ដាវីឌបានទៅយកដំបងនិងខ្សែដង្ហក់ដែលខ្លួនតែងប្រើនៅពេលដេញ សត្វតោ និងខ្លាឃ្មុំពេលឃ្វាលចៀម រួមជាមួយនិងដុំថ្មចំនួនប្រាំដុំដាក់ក្នុងថង់។
ពេលឃើញដាវីឌដែលចេញមកច្បាំងជាមួយខ្លួនភ្លាម កូលីយ៉ាតបានសើចចំអកដល់ដាវីឌជាខ្លាំង។
ប៉ុន្តែ ដាវីឌមិនមានការភ័យខ្លាចអ្វីសោះ។



ដាវីឌបានរត់សំដៅទៅរកកូលីយ៉ាតយ៉ាងលឿន ហើយបានគប់ដុំថ្មចំថ្ងាស់កូលីយ៉ាត។

យក្សកូលីយ៉ាត ក៏បានដួលចុះ ក្រោយត្រូវមួយដុំថ្មដែលហោះមកនោះ សន្លប់បាត់មាត់ឈឹង។

ដាវីឌបានចូលទៅឈរជិតកូលីយ៉ាតដោយនៅក្នុងដៃមិនមានដាវ ដាវីឌក៏បានយកដាវកូលីយ៉ាតមកកាត់ផ្តាច់កកូលីយ៉ាតទៅ។

ជនជាតិភីលីស្ទីនដែលបានឃើញហេតុការណ៍នេះ មានការភ័យខ្លាចជាខ្លាំង ក៏រត់បាស់ជើងគ្រប់គ្នា។ នៅថ្ងៃនោះ ជ័យជម្នះដ៏ធំក៏កើតមានលើរាស្ត្រអ៊ីស្រាអែល។

ពេលដាវីឌឃ្វាលចៀមហើយមានសត្វសាហាវៗដូចជាសត្វតោ និងខ្លាឃ្មុំ បានលេចមក ពេលនោះគាត់តែងជឿលើ ព្រះជាម្ចាស់ ហើយពឹងផ្អែកលើទ្រង់ ដែលនាំឱ្យគាត់អាចយកឈ្នះលើសត្រូវបានដោយកម្លាំងដែលមកពីព្រះជាម្ចាស់ ។

ដំបូងឡើយ ដាវីឌបានយកឈ្នះលើសត្វតោ ឬខ្លាឃ្មុំ ប៉ុន្តែ ពេលនេះ  ដាវីឌក៏បានយកឈ្នះលើមេទ័ពកូលីយ៉ាតដែល មានមាឌធំដូចយក្ស ដែលបានមកគំរាមគំហែងរាស្ត្រអ៊ីស្រាអែលនោះ ក្រោយពីនោះ គាត់បានសង្គ្រោះអ៊ីស្រាអែល និងទទួលបានជ័យជម្នះដ៏អស្ចារ្យ។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើដាវីឌជឿថាអ្នកណានឹងជួយគាត់ឱ្យយកឈ្នះលើពួកហ្វីលីស្ទីន និងកូលីយ៉ាត?

---

b. តើដាវីឌបានយកអ្វីទៅជាមួយនៅពេលគាត់ទៅច្បាំងនឹងកូលីយ៉ាត?

---

c. សូមអាន១សាំយូអែល១៧៖៤១-៥៤ រួចឆ្លើយសំណួរ។ តើដាវីឌបាននិយាយអ្វីខ្លះទៅកាន់កូលីយ៉ាត? ចូរនិយាយឱ្យខ្លាំងៗដូចដាវីឌ។

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (១សាំយូអែល១៧៖៤៥)

> ដាវីឌឆ្លើយទៅវិញថា៖ «ឯងកាន់ដាវ កាន់លំពែង និងស្នា មកវាយអញ រីឯអញវិញ អញមកវាយឯង ក្នុងនាម ព្រះអម្ចាស់ នៃពិភពទាំងមូល

**សកម្មភាពទី២** សូមបង្កើតរ៉ូឡែត(ថាសបង្វិល) រឿងដាវីឌ និងកូលីយ៉ាតដូចខាងក្រោម។

សម្ភារៈ ៖ កន្ត្រៃ ប្រដាប់ខ្ទាស់




